**ជួយឧបត្ថម្ភកំណត់ត្រា មានន័យថាជួយឧបត្ថម្ភដល់គំរោងប្រយុទ្ធនឹងភាពក្រីក្រចំនួន ៨៧០ ក្នុងប្រទេសចំនួន ៧០ និងជួយមនុស្សជាង ៤៥ លាននាក់ ។**

# overland-underwater.com

## មិត្តនាំងអស់ជាទីរាប់អាន

នៅលើលោកនេះ ជីវិតរស់នៅរបស់មនុស្សកាន់តែច្រើនទៅៗកំពុងត្រូវបានលើកកំពស់ដោយផ្ទាល់ដោយសារសកម្មភាពនានារបស់គំរោង ដែលបាន និងកំពុងអនុវត្តដោយអង្គការឃែអន្តរជាតិ ។ គោលបំណងរបស់អង្គការគឺបំរើបុគ្គល និងគ្រួសារទាំងឡាយ ដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្របំផុតនៅទូទាំងពិភពលោក ។

ដើម្បីជួយលើកកំពស់ការយល់ដឹងពីកិច្ចការ និងបេសកកម្មដ៏ខាន់របស់អង្គការឃែអន្តរជាតិនេះ ក្រុមធ្វើដំណើរស្វែងរកជំនួយឧបត្ថម្ភ ឈ្មោះ ថា "overland-underwater" នឹងបើកបរចេញពីប្រទេសអង់គ្លេសទៅកាន់ប្រទេសនូវែលហ្សេឡង់ ដោយធ្វើដំណើរតាមផ្លូវគោកឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ គោលបំណងនៃការធ្វើដំណើរនេះគឺដើម្បីរៃប្រាក់មួយចំនួន តាមរយៈការបរិច្ចាគ ការសន្យាឧបត្ថម្ភ និងការផ្តល់ហិរញ្ញវត្ថុដល់អង្គការឃែអន្តរជាតិ ។

យើងនឹងធ្វើដំណើរក្នុងចំងាយផ្លូវ ៦៥០០០ គីឡូម៉ែត្រ ឆ្លងកាត់ ២៦ ប្រទេស ក្នុងទ្វីប ៤ ក្រោមសីតុណ្ហភាពពីកំរិត ៤០ អង្សាសេនៅវាលរហោឋានមជ្ឈឹមបូពិារហូតដល់កំរិតក្រោម ២០ អង្សាសេ នៅពេលឆ្លងកាត់ភ្នំហេមពាន្ត និងបើកបរលើថ្ម ខ្សាច់ ភក់ ទឹកកក និងជួលកាលលើកំណាត់ផ្លូវគ្រួសគ្រាយថ្មីមួយចំនួន !

***ការធ្វើដំណើរនេះរៀបចំឡើងក្រោមការជួយឧបត្ថម្ភពីអង្គការឃែអន្តរជាតិ ប៉ុន្តែការចំណាយទាំងអស់សំរាប់ធ្វើដំណើរគឺជាបន្ទុករបស់ក្រុម ។***

យើងកំណត់ពេលវេលាចេញដំណើរពីប្រទេសអង់គ្លេសនៅដើមខែសីហា ឆ្នាំ ២០០៥ និងត្រូវចំណាយពេល ១៨ ខែទើបទៅដល់ប្រទេសគោលដៅ ។ យើងមានបំណងចង់លើកកំពស់បេសកកម្មការងាររបស់អង្គការឃែអន្តរជាតិ ហើយយើងនឹងទៅធ្វើទស្សនកិច្ចគំរោងមួយចំនួនក្នុងពេលធ្វើដំណើរតាមផ្លូវ ។

ប្រសិនបើចង់ដឹងព័ត៌មានអំលិត និងព័ត៌មានថ្មីៗអំពីការធ្វើដំណើរនេះ សូមអានគេហទំព័រ របស់យើង: www.overland-underwater.com ។ លោក លោកស្រីអាចបរិច្ចាគដោយប្រើប្រព័ន្ធអ៊ីនធឺណិតភ្ជាប់ទៅនឹងគេហទំព័ររបស់យើង ឬក៏បើកទំរង់សំរាប់កិច្ចសន្យាឧបត្ថម្ភ/ផ្តល់ហិរញ្ញវត្ថុ និងផ្ញើតាមប្រៃសនីយ៍នូវបរិច្ចាគរបស់លោក លោកស្រីទៅកាន់អង្គការឃែអន្តរជាតិ ។

**ផ្លូវធ្វើដំណើរ :**
អង់គ្លេស បារាំង អ៊ីតាលី ស្លូវ៉ានៀ ក្រូអាត សែប៊ី និងម៉ុងត៏ ប៊ុលការី ទួគី ស៊ីរី ហ្សដានី អ៊ីហ្សីប អ៊ីរ៉ង់ ប៉ាគីស្ថាន ឥណ្ឌា នេប៉ាល់ ចិន ឡាវ ថៃ ហ្វីលីពីន កម្ពុជា ម៉ាលេស៊ី សឹង្ហបូរី ឥណ្ឌូនេស៊ី ប៉ាពួញូវហ្គីនេ អូស្រ្តាលី នូវែលហ្សេឡង់

ចង់ដឹងព័ត៌មានបន្ថែម សូមអានគេហទំព័រ: www.overland-underwater.com

ឬសរសេរអ៊ីមេលមកកាន់យើងតាម: team@overland-underwater.com

ស្វែងរកពិភពលោកមួយប្រកបដោយក្តីសង្ឃឹម ភាពអត់អោន និងយុត្តិធម៌សង្គម គឺត្រូវបំបាត់ភាពក្រីក្រ ហើយមនុស្សរស់នៅប្រកបដោយភាពថ្លៃថ្នូរ និង សុវត្ថិភាព ។

## អង្គការឃែរអន្តរជាតិជួយសំរួលដល់ការផ្លាស់ប្តូរយូរអង្វែងតាមរយៈ :

### ពង្រឹងសមត្ថភាពសំរាប់ជួយខ្លួនឯង - ផ្តល់ឱកាសសេដ្ឋកិច្ច






### ផ្តល់ជំនួយសង្គ្រោះបន្ទាន់ - ជំរុញឱ្យមានការកែប្រែការធ្វើសេចក្តីសំរេចខាងនយោបាយនៅគ្រប់កំរិតទាំងអស់






សិស្សចំនួន ១ លាននាក់ ដែលក្នុងនោះមានសិស្សស្រីចំនួនពាក់កណ្តាល បានទទួលផលពីគំរោងនានា ដែលជួយដល់ការលើកកំពស់ការចុះឈ្មោះចូលរៀនក្នុងសាលា និងលើកកំពស់គុណភាពនៃការអប់រំ ។

បុរស ស្ត្រី និងកុមារចំនួន ៧.៦ លាននាក់បានទទួលជំនួយសង្គ្រោះបន្ទាន់ ដូចជា អាហារ ទឹក និងទីជំរក ដែលជាតំរូវការចាំបាច់ក្នុងពេលមាន វិបត្តិ ។

មនុស្សជាង ៧ លាននាក់បានទទួលព័តិមានអំពីការពារការរាលដាលនៃមេរោគអេដស៏ និងជំងឺអេដស៏ ដែលការនេះជួយកាត់បន្ថយការឈឺចាប់ដែលបណ្តាលមកពីវិបត្តិមួយក្នុងចំណោមវិបត្តិនានាក្នុងសម័យកាលយើងនេះ ។

មាតា និងកុមារស្ទើរតែ ៩ លាននាក់មានលទ្ធភាពទទួលបានប្រសើរជាងមុននូវសេវាកម្មសុខភាពក្រុបដោយគុណភាព ដោយការធ្វើឱ្យមានសុវត្ថិភាពជាងមុននូវការមានផ្ទៃពោះ សំរាល និងភាពជាទារក ។

មនុស្សជាង ៦.៥ លាននាក់បានទទួលការបណ្តុះបណ្តាល និង/ឬធនធានដើម្បីលើកកំពស់ដំណាំ និងដើម្បីការពារធនធាន ធម្មជាតិ ដែលឈានទៅរកដំណោះស្រាយភាពអត់ឃ្លានប្រកបដោយនិរន្តរភាព ។

មនុស្សជាង ១ លាននាក់ ដែលពាក់កណ្តាលជាស្ត្រីបានទទួលប្រយោជន៏ពីគំរោងនានា ដែលជួយដល់ការបង្ហាត់បង្រៀនជំនាញធ្វើជំនួញ លើកកំពស់លទ្ធភាពដល់ការទទួលឥណទាន និងជួយប្រជាជនចាប់ផ្តើម និងធ្វើជំនួញខ្នាតតូចប្រកបដោយនិរន្តរភាព ។

**ដោយអនុវត្តតាមក្តីប្រាថ្នារបស់សហគមន៍មូលដ្ឋាន អង្គការឃែរអន្តរជាតិមានបេសកកម្មក្រុបដោយភាពអស្ចារ្យ និងការប្តេជ្ញាចិត្តខ្ពស់ ពីព្រោះថាមនុស្សដែលអង្គការជួយទទួលប្រយោជន៏ដូចគ្នា ។**

CARE International UK,
10-13 Rushworth Street,
London. SE1 0RB. UK.
Tel: +44 (0) 20 7934 9334
Fax: +44 (0) 20 7934 9335
Email: info@ciuk.org
www.careinternational.org.uk

ឯកសារចុះបញ្ជីមេត្តាករុណាលេខ : ២៩២៥០៦